# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ
## ក្រោមប្រធានបទ ៖ ពលករខ្មែរដែលធ្វើការនៅបរទេស
## ត្រូវគេរំលោភច្បាប់ការងារ ។

**Website: www.hoksavann.org**

ថ្ងៃទី២២ សីហា ២០១០



ប្រទេសកម្ពុជាចាត់ចូលក្នុងប្រទេសដែលកំពុងមានការលូតលាស់ ប៉ុន្តែប្រជាពលរដ្ឋនៅតែមានភាពក្រីក្រ ផ្សំគ្នានឹងវិបត្តិសេដ្ឋកិច្ចពិភពលោកផង ។ សព្វថ្ងៃនេះប្រជាពលរដ្ឋខ្មែរគ្មានការងារធ្វើមានចំនួនកាន់តែច្រើនឡើង ជាពិសេសនិស្សិតដែលចេញពីសាលាប្រឡងជាប់ចំពោះមុខវិជ្ជាក៏វិតណាមួយ ក្រសួងការងារនៃរដ្ឋពុំបានចាត់ចែងឲ្យមានការងារធ្វើបានម៉ត់ចត់ឡើយ ។

ដោយភាពក្រីក្រនិងកង្វះការងារធ្វើក្នុងប្រទេសរបស់ខ្លួន ពលរដ្ឋខ្មែរមានចំនួនកាន់តែច្រើនធ្វើចំណាកស្រុកទៅរកស៊ីនៅបរទេស ។ តាមពត៌មានថា ក្រុមហ៊ុនស្របច្បាប់២៦និងក្រុមហ៊ុនមិនស្របច្បាប់ជាច្រើនទៀតបានបញ្ជូនពលករខ្មែរ ឲ្យទៅធ្វើការនៅបរទេស ។ ពត៌មាននោះបានបញ្ជាក់ទៀតថា ពលករខ្មែរដែលបានទៅធ្វើការនៅប្រទេសថៃមានចំនួន២សែននាក់ ។ នៅប្រទេសម៉ាឡេស៊ី២ម៉ឺននាក់ ។ នៅប្រទេសកូរ៉េខាងត្បូង៩ពាន់នាក់ ។ តាមពត៌មានគួរឲ្យរន្ធត់ថា ពលករខ្មែរទាំងនោះភាគច្រើនបានត្រូវគេរំលោភ ជាពិសេសពលករខ្មែរដែលធ្វើការបំរើតាមផ្ទះនៅប្រទេសម៉ាឡេស៊ី ។ ស្ត្រីខ្មែរដែលបំរើតាមផ្ទះទាំងនោះ បំរើគេដូចទាសករដាច់ថ្លៃ ធ្វើការតាំងពីព្រលឹមដល់ពាក់កណ្តាលអធ្រាត អាហារមិនគ្រប់គ្រាន់ បំរើពុំគាប់ចិត្តម្ចាស់ផ្ទះត្រូវគេវាយធ្វើបាប បង្អត់អាហារ ត្រូវគេរំលោភផ្លូវភេទ មានស្ត្រីខ្មែរខ្លះត្រូវម្ចាស់ផ្ទះរំលោភទាំងគ្រួសារវាតែម្តង ។ ក្រុមហ៊ុននៅក្នុងស្រុក ក៏ដូចគ្នានឹងក្រុមហ៊ុននៅក្រៅស្រុក បានរំលោភច្បាប់ការងារ ទោះបីមានកិច្ចសន្យារវាងពលករនិងក្រុមហ៊ុន ក៏ស្ថិតនៅតែលើក្រដាស គ្មានបានអនុវត្តឲ្យបានត្រឹមត្រូវឡើយ ។ ដូចជាពេលទៅដល់ ត្រូវគេដកលិខិតឆ្លងដែន កាត់ប្រាក់ខែដោយគ្មានមូលហេតុ ពេលគេធ្វើទុក្ខបុកម្នេញ គ្មានអ្នកទទួលខុសត្រូវក្រុមហ៊ុនចេញមុខជួយការពារឡើយ ។

កាលពីពេលមុន យើងបានទទួលពត៌មានពីសមាគមខ្មែរនៅចិនតៃវ៉ាន់ថា ស្ត្រីខ្មែរចំនួនជាង៥ពាន់នាក់បានទៅដល់ចិនតៃវ៉ាន់តាមរយៈអាពាហ៍ពិពាហ៍ក្លែងក្លាយ បានត្រូវគេលក់បន្តឲ្យធ្វើជាស្រីពេស្យា ឲ្យធ្វើការក្នុងរោងចក្រដោយឲ្យតម្លៃថោក ស្ត្រីខ្មែរតិចណាស់ដែលប្រុសតៃវ៉ាន់យកទៅធ្វើជាប្រពន្ធត្រឹមត្រូវ ។ គេបញ្ជាក់ថា ប្រុសចិនតៃវ៉ាន់ដែលមករកប្រពន្ធនៅបរទេស ជាពិសេសប្រទេសកម្ពុជានេះ ជាប្រុសអស់សាច់ ពាលាអាវ៉ាសែ ខ្លះចាស់ ខ្លះពិការផង ដែលស្រីតៃវ៉ាន់គេមិនត្រូវការ ។ ដោយស្ត្រីខ្មែរទាំងនោះចូលទៅចិនតៃវ៉ាន់ដោយខុសច្បាប់ ម្ល៉ោះហើយពេលមានទុក្ខម្តងៗ ពិបាកឲ្យរដ្ឋតៃវ៉ាន់ការពារតាមផ្លូវច្បាប់ណាស់ ។ ពឹងរាជរដ្ឋាភិបាលខ្មែរ ខ្មែរពុំមានឯកអគ្គរាជទូតនៅចិនតៃវ៉ាន់ឡើយ ពឹងបានតែអង្គការក្រៅរដ្ឋាភិបាលខ្លះនៅចិនតៃវ៉ាន់ប៉ុណ្ណោះ ។ ត្រង់វិបត្តិដ៏ធ្ងន់ធ្ងរនេះហើយ បានជាពេលនោះយើងបានទទួលពត៌មានថា ព្រះករុណាព្រះបាទសម្តេចនរោត្តម-សីហនុ ព្រះអតីតព្រះមហាក្សត្រខ្មែរព្រះអង្គប្រកាសថា ព្រះអង្គនឹងចេញថ្លៃយន្តហោះ បើស្ត្រីខ្មែរជាកូនចៅព្រះអង្គចង់ត្រឡប់ពីចិនតៃវ៉ាន់មកកម្ពុជាវិញ ។ ស្ត្រីខ្មែរជាង៥ពាន់នាក់ចេញពីប្រទេសកម្ពុជាដោយផ្លូវងងឹត ។ រាជរដ្ឋាភិបាលខ្មែរគ្មានចាត់ការទប់ទល់អ្វីសោះ ដូច្នេះគេជឿជាក់ឥតសង្ស័យថា ពិតជាមានមន្ត្រីអ្នកមានអំណាចនៅពីក្រោយនៃការរត់ពន្ធមនុស្សនេះ ដែលសហរដ្ឋអាមេរិកក៏បានធ្វើសេចក្តីថ្លែងការណ៍ថ្កោលទោសជាញឹកញាប់ ។

យើងលើកយកព្រឹត្តិការណ៍ស្ត្រីខ្មែរនៅចិនតៃវ៉ាន់នេះមករៀបរាប់ឡើងវិញ ដើម្បីយកមកប្រៀបធៀបមើលពលករខ្មែរនៅប្រទេសដែលមានឯកអគ្គរាជទូតខ្មែរ និងមានក្រុមហ៊ុនស្របច្បាប់ ដែលក្រសួងការងារខ្មែរត្រួតពិនិត្យផង គួរតែការរំលោភត្រូវបាត់បង់ ប៉ុន្តែការរំលោភនៅតែមានជាច្រើនករណីមកលើពលករខ្មែរ ដែលអង្គការក្រៅរដ្ឋាភិបាលបានប្រកាសផ្សាយ ។ បើមានការរំលោភលើពលករខ្មែរពីសំណាក់ក្រុមហ៊ុន ឯកអគ្គរាជទូតខ្មែរប្រចាំប្រទេសទាំងនោះ ហាក់ដូចជាព្រងើយកន្តើយពុំយកចិត្តទុកដាក់ជួយដោះស្រាយឡើយ ។ ចំណែកក្រសួងការងារនៃរាជរដ្ឋាភិបាលក៏ពុំបានដាក់វិធានការឲ្យម៉ឺងម៉ាត់ចំពោះក្រុមហ៊ុនរំលោភច្បាប់ការងារទាំងនោះ ។ មួយទៀត ក្រសួងការងារនារីនិងកាកបាទក្រហម ដែលចាត់ទុកស្ត្រីខ្មែរជានារីរតនៈ លើកតម្កើងសីលធម៌សង្គម និងតម្លៃស្ត្រីខ្មែរ ក៏គ្មានឃើញធ្វើអតន្តរាគមន៍អ្វីសោះ ពេលដែលឮស្ត្រីខ្មែរបំរើតាមផ្ទះត្រូវគេរំលោភនៅម៉ាឡេស៊ី ។ រាជរដ្ឋាភិបាលគប្បីបង្កើតការងារឲ្យប្រជាពលរដ្ឋធ្វើ ដើម្បីបន្ថយពលករចំណាកស្រុក ដែលនាំឲ្យគេប្រមាថមើលងាយ ។ ចំណែកពលករខ្មែរក៏គប្បីពិចារណាមុននឹងផ្សងព្រេងទៅធ្វើការនៅបរទេស កុំចាញ់បោកមេខ្យល់ ។ បញ្ហាមួយទៀត ដែលនាំឲ្យពលរដ្ឋខ្មែរចង់ទៅធ្វើការនៅបរទេសទោះបីឆ្លងកាត់គ្រោះថ្នាក់ គឺបញ្ហាប្រាក់ខែតិចធ្វើការក្នុងស្រុកពុំអាចរស់បាន ។ ក្នុងពេលថ្មីៗនេះ ក្រុមកម្មកររោងចក្រកាត់ដេរជាច្រើនម៉ឺននាក់ បានច្រានចោលប្រាក់បន្ថែម៥ដុល្លារទៅលើប្រាក់ខែគោលត្រូវជា៦០ដុល្លារ ដែលក្រុមប្រឹក្សាការងារបានបន្ថែម ដោយប្រាក់ខែប៉ុណ្ណោះពុំអាចរស់បានឡើយ ដោយសុំតម្លើងពី៧០ដុល្លារដល់៩០ដុល្លារក្នុងមួយខែ ទើបអាចរស់បានជាបង្គួរក្នុងពេលដែលទំនិញសព្វសារពើបានឡើងថ្លៃ ។ ប្រធានសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា បានប្រកាសគំរាមដឹកនាំកម្មកររាប់ម៉ឺននាក់ធ្វើកូដកម្ម បើមិនតម្លើងតាមសំណើសុំនេះទេ ដូច្នេះត្រូវក្រសួងការងារ សមាគមរោងចក្រកាត់ដេរពិចារណាឡើងវិញ ។ ចម្លើយតបរបស់ក្រសួងការងារបាននិយាយប្រមាថមើលងាយកម្មករថា អំពើនេះជាការផ្តួលរំលំឆ្នាំងបាយខ្លួនឯង ។ ពាក្យគ្មានទទួលខុសត្រូវនេះ ជាពាក្យប្រមាថផង ឲ្យដៃដល់ក្រុមហ៊ុនផង ។ ការតម្លើង៥ដុល្លារនេះសំរាប់៤ឆ្នាំទើបនិយាយគ្នាម្តងទៀត ។ ៤ឆ្នាំទៅមុខ តើទំនិញសព្វសារពើលើងថ្លៃដល់កំរិតណា បើប្រាក់ខែនៅដដែល ។ ក្រុមប្រឹក្សាការងារបានសំរេចគ្មានសមធម៌ឡើយ ។៚